【ជនជាតិបរទេសក៏អាចទទួលបានម្នាក់ដប់មុឺន(100,000YEN)យ៉េនដែរ។】

មេរោគកូរ៉ូណាឆ្លងថ្មី（covid19）រដ្ឋាភិបាលនឹងផ្តល់ប្រាក់អោយម្នាក់ ១០០,០០០ យ៉េនដល់អ្នកដែលរស់នៅក្នុងប្រទេសជប៉ុនទាំងអស់គ្នា។
អ្នកដែលអាចទទួលបានប្រាក់ដប់មុឺន(100,000YEN)គឺ「អ្នកដែលមានចុះឈ្មោះ『ចុះឈ្មោះជាមូលដ្ឋាន』ត្រឹមថ្ងៃទី២៧ខែមេសាទាំងអស់គ្នា」
ជនជាតិបរទេសក៏អាចទទួលលុយនេះបានដែរ។
ក្រសួងកិច្ចការផ្ទៃក្នុងនិងការទំនាក់ទំនងបានប្រកាសនៅថ្ងៃទី២០នេះ។

សម្រាប់ជនបរទេសដើម្បីទទួលបានប្រាក់ អ្នកត្រូវការមានលក្ខខណ្ឌដូចខាងក្រោមនេះត្រឹមថ្ងៃទី២៧ខែមេសា។
・អ្នកដែលមានប័ណ្ណស្នាក់នៅក្នុងប្រទេសជប៉ុនលើសពី៣ខែឡើងទៅ (សិទ្ធិស្នាក់នៅ)
・បានចុះឈ្មោះនៅការិយាល័យរដ្ឋាភិបាលដែលអ្នករស់នៅ「ប័ណ្ណបញ្ជាក់ទីលំនៅ」

ពីការិយាល័យរដ្ឋាភិបាលដែលអ្នកចុះឈ្មោះប័ណ្ណស្នាក់នៅរបស់អ្នក,នឹងផ្ញើ「ទម្រង់ពាក្យស្នើសុំ」ទៅផ្ទះរបស់អ្នក ដើម្បីទទួលប្រាក់។
នៅក្នុងទម្រង់ពាក្យស្នើសុំ សូមសរសេរឈ្មោះមេគ្រួសារ (ឪពុក។ល។) ថ្ងៃកើត (ថ្ងៃខែឆ្នាំកំណើត) ទីកន្លែងស្នាក់នៅ (អាសយដ្ឋាន)
សូមសរសេរគណនីធនាគារដែលអ្នកផ្ទេរប្រាក់ ហើយសូមផ្ញើទៅការិយាល័យរដ្ឋាភិបាលវិញផង។
សូមផ្ញើសៀវភៅគណនីធនាគារនឹង ថតចម្លងឯកសារបញ្ជាក់សម្គាល់ខ្លួនមកជាមួយផង។

អ្នកដែលមានកាត(ម៉ាយណាំប៊ឺ)សម្គាល់ប្រចាំខ្លួន, អ្នកអាចដាក់ពាក្យស្នើសុំតាមអ៊ិនធឺរណេតបាន។

ថ្ងៃដែលទម្រង់ពាក្យស្នើសុំមកដល់ ឬក៏ថ្ងៃដែលអ្នកអាចទទួលប្រាក់បាន អាស្រ័យទៅលើក្រុងដែលអ្នករស់នៅ។
កន្លែងដែលលឿនជាងគេ ពាក់កណ្តាលខែឧសភានឹងបានចាប់ផ្តើម។

បើសិន អំពីការ「ចុះឈ្មោះជាមូលដ្ឋាន」ឬ「ប័ណ្ណបញ្ជាក់ស្នាក់នៅ」ឬក៏អ្នកមានសំណួរ អ្នកអាចពិគ្រោះយោបល់តាមទូរស័ព្ទបាន។
មានអ្នកប្រចាំការនៅមជ្ឈមណ្ឌលទទួលពិគ្រោះនឹងអ្នកសាលាក្រុង នឹងជួយបកប្រែអោយផងដែរ។

មជ្ឈមណ្ឌលទទួលពិគ្រោះនៃក្រសួងកិច្ចការផ្ទៃក្នុងនិងទំនាក់ទំនង
0570-066-630（ណាប៊ីដាយយ៉ារី）
03-6436-3605（ពេលទូរស័ព្ទតាម ទូរស័ព្ទIP、PHS）
8：30～17：30
ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃបុណ្យគឺជាថ្ងៃឈប់សម្រាក។
ភាសាជប៉ុន, ភាសាអង់គ្លេស, ភាសាចិន, ភាសាកូរ៉េ, ភាសាអេស្ប៉ាញ, ភាសាព័រទុយហ្កាល់, ភាសាវៀតណាម, ភាសាថៃ, ភាសាឥណ្ឌូណេស៊ី, ភាសាតាហ្គាស, ភាសានេប៉ាល់ អ្នកអាចពិគ្រោះយោបល់បាន។
ការពន្យល់ពីជនបរទេស『ការចុះឈ្មោះជាមូលដ្ឋាន』។ មានគេហទំព័រជាភាសាផ្សេងៗផងដែរ។
https://www.soumu.go.jp/main_sosiki/jichi_gyousei/c-gyousei/zairyu/

ប្រភព៖
「ជនជាតិបរទេសក៏អាចទទួលបានដប់មុឺន(100,000YEN)យ៉េនដែរ។」（ព័ត៌មានជប៉ុនស្រួលៗ / Withhnews, Asahi Shimbun ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០）
URL:https://www.facebook.com/yasashiinews/